# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាអាទិត្យទី២នៃរដូវរង់ចាំនៅព្រះសហគមន៍សន្តិនៃសន្តិភាព
# អរិយក្សេត្រ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩
# ព្រះនាងម៉ារីជាគំរូនៃជីវិតដ៏វិសុទ្ធ

**អត្ថបទទី១៖ អេសាយ ១១,១-១០**

ព្រះអង្គនឹងយកយុត្តិធម៌ធ្វើជាខ្សែក្រវាត់ចង្កេះ យកព្រះហឫទ័យស្មោះត្រង់ធ្វើជាសង្វារ។ អស ១១,៥

**អត្ថបទទី២៖ រ៉ូម ១៥,៤-៩**

អ្វីៗដែលមានចែងទុកពីមុនមក គឺចែងទុកសម្រាប់អប់រំយើង ដោយគម្ពីរជួយសម្រាលទុក្ខយើងនិងឲ្យយើងចេះស៊ូទ្រាំ យើងមានសេចក្ដីសង្ឃឹម។ រម ១៥,៤

**ដំណឹងល្អ៖ ម៉ាថាយ ៣,១-១២**

ចូរប្រព្រឹត្តអំពើល្អ ដើម្បីបញ្ជាក់ថា អ្នករាល់គ្នាបានកែប្រែចិត្តគំនិតមែន។ មថ ៣,៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងមកយ៉ាងច្រើនដើម្បីអធិដ្ឋានជាមួយព្រះនាងម៉ារី ឲ្យយើងចេះទទួលស្វាគមន៍ព្រះយេស៊ូនៅក្នុងជីវិតរបស់យើង។ យើងបានស្ដាប់ដំណឹងល្អដ៏ពិសេស គឺព្រះនាងម៉ារីទៅជាម្ដាយរបស់ព្រះយេស៊ូ នៅក្នុងរដូវរង់ចាំនេះ **តើព្រះនាងម៉ារីណែនាំឲ្យយើងរៀបចំចិត្តគំនិតដូចម្ដេចដើម្បីទទួលស្វាគមន៍ព្រះយេស៊ូដែលកំពុងយាងមក?** នៅក្នុងរដូវរង់ចាំនេះ ខ្ញុំអញ្ជើញបងប្អូនគ្រីស្តបរិស័ទយើងធ្វើដំណើរជាមួយសម្ដេចប៉ាប ណែនាំឲ្យយើងគិតរួមជាមួយព្រះនាងម៉ារី ឲ្យយើងបង្កើតចិត្តគំនិតមួយដ៏កក់ក្ដៅដើម្បីឲ្យព្រះយេស៊ូប្រសូតបាន។

**ទីមួយ** ឲ្យយើងថែរក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ជាអាទិភាព ដើម្បីដឹកនាំជីវិតរបស់យើង ថ្ងៃនេះគឺព្រះនាងម៉ារីដែលស្ដាប់ទេវទូតកាព្រីអែល ដែលបានណែនាំព្រះបន្ទូលរបស់ព្រះជាម្ចាស់យាងចូលនៅក្នុងដួងចិត្តរបស់ព្រះនាងម៉ារី ដើម្បីឲ្យព្រះនាងម៉ារីធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយឯកភាពធ្វើជាមាតារបស់ព្រះយេស៊ូ និងឯកភាពទទួលព្រះបន្ទូលរបស់ព្រះអង្គឲ្យចាប់កំណើតជាមនុស្ស។ កុំឲ្យយើងធ្វើតាមចិត្ត ឲ្យយើងធ្វើតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដូច្នេះពីមួយថ្ងៃទៅមួយថ្ងៃសូមយកចិត្តទុកដាក់ស្ដាប់ព្រះបន្ទូល ដើម្បីនឹកឃើញ **តើព្រះបន្ទូលរបស់ព្រះជាម្ចាស់ដឹកនាំជីវិតរបស់ខ្ញុំដូចម្ដេច?**

**ទីពីរ** ឲ្យយើងយកចិត្តទុកដាក់អធិដ្ឋាន ដូចព្រះនាងម៉ារីលើកតម្កើងព្រះជាម្ចាស់ ឲ្យជីវិតរបស់យើងរស់នៅក្នុងបរិយាកាសអធិដ្ឋានជានិច្ច។

**ទីបី** ឲ្យយើងមានចិត្តស្វាគមន៍ ព្រះនាងម៉ារីបានស្វាគមន៍ព្រះយេស៊ូ ឲ្យយើងមានចិត្តគំនិតដើម្បីស្វាគមន៍ព្រះយេស៊ូនិងបងប្អូនឯទៀតៗ។ យើងត្រូវការសម្រេចចិត្តនៅមុខព្រះនាងម៉ារីថ្ងៃនេះ នៅក្នុងរដូវរង់ចាំ **តើខ្ញុំផ្ទាល់ខ្លួនបានធ្វើអ្វីខ្លះដើម្បីស្រឡាញ់ ស្វាគមន៍ លើកទឹកចិត្តអ្នកជំងឺ អ្នកតូចតាច អ្នកដែលគ្មានទីពឹង?** ឲ្យយើងធ្វើពិតៗ ដោយអធិដ្ឋានជាមួយព្រះនាងម៉ារី។

**ទីបួន** ឲ្យយើងយកចិត្តទុកដាក់ស្រឡាញ់និងបម្រើ នេះជាជីវិតរបស់យើងជាគ្រីស្តបរិស័ទត្រូវតែស្រឡាញ់និងបម្រើបងប្អូនឯទៀតៗ។

**ទីប្រាំ** ឲ្យយើងទុកចិត្តលើព្រះជាម្ចាស់ជានិច្ច ដូចព្រះនាងម៉ារីដែលមានទុក្ខលំបាកយ៉ាងច្រើន ប៉ុន្តែព្រះនាងម៉ារីបន្តទុកចិត្តលើព្រះជាម្ចាស់ ដោយដឹងថាព្រះជាម្ចាស់ស្រឡាញ់យើង។ គ្រប់សកម្មភាពដែលព្រះនាងម៉ារីបានធ្វើ នៅក្នុងដំណើរជីវិតរបស់យើងអំណរសប្បាយក្តី សេចក្តីសង្ឃឹមក្តី ទុក្ខលំបាកក្តី ដឹងថាយើងត្រូវទុកចិត្តលើព្រះជាម្ចាស់។ ជីវិតរបស់យើងក៏ដូចគ្នា ឲ្យយើងអធិដ្ឋាននៅក្បែរឈើឆ្កាងដោយដឹងថាព្រះជាម្ចាស់គង់នៅ ឲ្យយើងទុកចិត្តលើព្រះជាម្ចាស់ជានិច្ច។

នេះទាំងអស់ ដើម្បីឲ្យយើងរួមគ្នាទៅជាអ្នកដ៏វិសុទ្ធ ព្រះនាងម៉ារីពោរពេញដោយភាពដ៏វិសុទ្ធ ព្រះនាងម៉ារីជាគំរូនៃជីវិតដ៏វិសុទ្ធសម្រាប់យើង។ ព្រះនាងម៉ារីបានឡើងស្ថានបរមសុខមុនគេបង្អស់ សព្វថ្ងៃព្រះនាងម៉ារីដូចជាកំពុងចាប់ដៃយើង ដើម្បីឲ្យយើងចូលនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់លើផែនដីនេះ ដោយត្រៀមខ្លួនចូលនៅក្នុងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គនៅស្ថានបរមសុខ។ យើងធ្វើដូចម្តេចដើម្បីទៅជាអ្នកដ៏វិសុទ្ធដូចព្រះនាងម៉ារី ព្រះនាងម៉ារីជាស្ត្រីម្នាក់ធម្មតាតែព្រះជាម្ចាស់បានជ្រើសរើសដើម្បីទៅជាអ្នកដ៏វិសុទ្ធបំផុត អ្នកដែលគ្មានជំពាក់បាបណែនាំឲ្យយើងមានសេចក្តីសង្ឃឹម ទោះបីយើងមានជំពាក់បាប យើងដឹងថាបន្តិចម្តងៗព្រះនាងម៉ារីធ្វើដំណើរជាមួយយើង ដើម្បីរកឃើញជីវិតដ៏វិសុទ្ធនៅលើផែនដីនេះ និងនៅស្ថានបរមសុខនាថ្ងៃអនាគត។ យើងអធិដ្ឋានសម្រាប់ព្រះសហគមន៍យើង សម្រាប់ជីវិតយើងសម្រាប់គ្រួសាររបស់យើង សម្រាប់សង្គមរបស់យើង ជាពិសេសយើងទូលអង្វរព្រះអង្គសូមព្រះអង្គប្រទានព្រះពរឲ្យយើងដូចព្រះអង្គបានប្រទានព្រះពរដល់ព្រះនាងម៉ារី ដើម្បីរួមគ្នាយើងធ្វើដំណើរទទួលស្វាគមន៍ព្រះយេស៊ូដែលកំពុងយាងមក។ យើងអធិដ្ឋាន ដើម្បីឲ្យឆ្នាំក្រោយយើងមានអភិបូជាដើម្បីប្រសិទ្ធីពរលើគ្រឹះ ដែលយើងសាងសង់ទីសក្ការៈសម្រាប់ព្រះនាងម៉ារីនៅកន្លែងថ្មី ដើម្បីឲ្យព្រះសហគមន៍កម្ពុជាយើងទៅជាពន្លឺដ៏តូចមួយសម្រាប់ប្រជាជនបច្ចុប្បន្ននេះ ដោយរកឃើញផ្លូវនៃជីវិត ផ្លូវនៃសេចក្តីស្រឡាញ់ និងផ្លូវនៃសុភមង្គលដ៏ពិតប្រាកដ។ ខ្ញុំសូមអធិដ្ឋាន ឲ្យយើងមានសេចក្តីសុខរួមជាមួយព្រះនាងម៉ារីនៅក្នុងរដូវរង់ចាំនេះ។ អាម៉ែន៕